# ទស្សនៈ តើអាណាចក្រអាចបង្ហាញសេចក្តីស្រលាញ់ឱ្យកាន់តែច្រើនដោយរបៀបណា?

ប្រែសម្រួលដោយៈ **សំរិទ្ធ មេត្តា**

ពីមួយឆ្នាំទៅមួយឆ្នាំចាប់តាំងពីថ្ងៃបុណ្យនៃសេចក្តីស្រលាញ់ចាប់ផ្តើមទទួលប្រជាប្រិយភាព ក្នុងប្រទេសកម្ពុជា។ ក៏មានអ្នកនិយាយថាផ្ទះសំណាក់ ឬក៏សណ្ឋាគាគូស្នេហ៍ គឺពោរពេញ ទៅដោយគូរស្នេហ៍ក្មេងៗដែលចង់រួមភេទ។ ធាតុពិតមានមនុស្សស្រីខ្លះបាត់បង់ ព្រហ្មចារីរបស់ខ្លួនដោយការស្រលាញ់ស្ម័គ្រស្មោះហើយអ្នកខ្លះបាត់បង់ដោយសារតែមាន សំពាធដែលតំរូវអោយធ្វើបែបនោះ។ នន្ទាការណ៍នេះបានធ្វើអោយមានការសួរសំនួរថាតើយើងអាចនឹងគួរតែបញ្ឈប់ពួកគេដែរឬទេ?

ទាំងនេះបានធ្វើអោយសេរីភាពនៃការរួមភេទមិនមានអ្វីប្លែកក្នុងប្រទេសកម្ពុជា ហើយនេះក៏ គ្មានអ្វីប្លែកក្នុងបុណ្យនៃក្តីស្រលាញ់ដែលពួកគេរួមភេទដែរ។ ព្រោះការរួមភេទសម្រាប់យុវវ័យ ក្នុងប្រទេសកម្ពុជាគឺមានជារៀងរាល់ថ្ងៃ មិនមែនមានតែថ្ងៃ១៤ កុម្ភៈនោះទេ។ ហើយក៏មានការ កំសាន្តនៅក្នុងក្លឹបផងដែរ បើទៅមើលក្នុង ស្រាបៀរ ហ្គាដិន គឺនឹងមានឃើញ ក្មេងស្រីស្អាតៗ ដែររងចាំបុរសក្មេងៗដែលចូលទៅទីនោះ។ តើយើងនៅតែបន្ទោសថ្ងៃបុណ្យនៃ សេចក្តីស្រលាញ់ចំពោះបញ្ហារួមភេទនេះដែរឬទេ?

តើអ្វីដែរយើងគួតែបារម្មណ៍នៅថ្ងៃបុណ្យនៃក្តីស្រលាញ់គឺការរួមភេទដែរមិនមានសុវត្ថិភាព ហើយនេះគឺជាការរួមចំនែកនៃកាជំរុញអោយចាស់ជំនាន់មុនមានព្រឹត្តិកម្មទៅលើការួមភេទ។ ដោយសារតែបញ្ហារនេះគឺធ្វើអោយមានការំខាន ដែលធ្វើអោយម្តាយឪពុកមិនហាននិយាយ និង ផ្តល់ដំបូន្មានដល់កូនៗរបស់ពួកគេអំពីបញ្ហារដែលទាក់ទងទៅនឹងការរួមភេទដែល មិនមានសុវត្ថិភាព។ ជាទូទៅម្តាយឪពុកតែងតែផ្តល់ដំបូន្មានមិនអោយមានការរួមភេទ មុនពេលរៀបអាពាហ៍ពិពាហ៍ ដែលកាផ្តល់ដំបូន្មានបែបនេះមិនសូវមានប្រសិទ្ធភាពទាល់ តែសោះ។

រវាងមនុស្សចាស់នឹងយុវវ័យគឺនៅតែមានគំលាត់ឆ្ងាយពីគ្នាខ្លាំងណាស់ក្នុងការទទួលយកសេច ក្តីស្រលាញ់នឹងការួមភេទ។ ជាកស្តែងដូចនៅថ្ងៃបុណ្យ

នៃក្តីស្រលាញ់ជាដើមដែលជាថ្ងៃ យុវវ័យចូលចិត្តខណៈពេលដែលចាស់ៗ មិនពេញចិត្តថ្ងៃនេះទាល់តែសោះ ជំនាន់ឪពុកម្តាយ របស់ខ្ញុំមិនសូវសំម្ដែង ឬបង្ហាញការស្រលាញ់ដាក់គ្នាទេ ផ្ទុយទៅវិញយុវវ័យនៅកម្ពុជាបានបង្ហាញក្តីស្រលាញ់ចំពោះគ្នាទាំងចិត្តទាំងកាយថែមទាំងមានការរួមភេទមុនពេលរៀបការ។

ឪពុកម្តាយនៅប្រទេសកម្ពុជាគឺមិនងាយបង្ហាញសេចក្តីស្រលាញ់ទៅកាន់កូនៗរបស់ពួកគេទេ។ហើយពួកគាត់ដែលបានចិញ្ចឹងអោយធំធាត់ក្នុងប្រទេសកម្ពុជាគឺប្រហែលជាមានការខ្មាស អៀននឹងភ័យខ្លាចនៅពេលដែលឃើញមនុស្សពីរនាក់ឈរអោបថើបគ្នានៅតាមដងផ្លូវ។ មាន មិត្តភក្តិម្នាក់គេប្រាប់ខ្ញុំថាគាត់បានអោបម្តាយរបស់គាត់លើកដំបូងនៅពេលដែលរូបគាត់អាយុ ២៤ឆ្នាំ។នេះក៏ដោយសារតែម្តាយរបស់គាត់ចាស់ជាងមុនផងដែរ ប៉ុន្តែក៏ធ្វើអោយរូបគាត់ជាកូនមាន អារម្មណ៍មិនសូវស្រួលផងដែរ។ គាត់និយាយថាគាត់មិនដែលបង្ហាញសេចក្តីស្រលាញ់នៅ ទីសាធារណៈឬនៅជុំវិញផ្ទះទេ។ រឿងបែបនេះគឺនៅតែមានចំពោះម្ចាស់ផ្ទះមួយចំនួន។

យើងត្រូវបានបង្រៀនអោយចេះនូវរបស់ជាច្រើនដូចជា ការអង្គុយ ឈរ ដើរ ញ៉ាំ និយាយ ស្លៀកពាក់ នឹងគោរពគ្នាទៅវិញទៅមក។ បុរសមិនគួរមើលស្ត្រីនឹងភ្នែកដោយផ្ទាល់ មិនគួប៉ះ ថើប ឬអោបខ្លួនស្ត្រីក្នុងកិច្ចស្វាគមន៍នោះទេ ពុំដូច្នោះទេស្ត្រីលែងមានការគោរព នឹងមានអារម្មណ៍ ខ្មាស់អៀនចំពោះបុរស់។ ពួកយើងទាំងអស់គ្នាត្រូវបានបង្រៀនក្បួនច្បាប់ជាច្រើនអំពីបញ្ហារនេះ ប៉ុន្តែតើ យើងមានបានបញ្ឈប់ ឬក៏សុំអោយឪពុកម្តាយរបស់យើងឈប់អោបថើបយើងប៉ុន្មានដង?

គំនិតដែលប្រឆាំងរបស់ខ្ញុំគឺចង់និយាយថាការអោបឬកាបង្ហាញសេចក្តីស្រលាញ់នៅទីសាធារណៈមិនមែនជាផ្នែកមួយនៃប្រពៃណីយើងទ។ ស្ទើតែគ្រប់ភាសារទាំងអស់ដែលមានពាក្យថា អោប ដូច្នេះវាមិនមានអ្វីភ្លែកនោះទេ ប៉ុន្តែហេតុអ្វីក៏យើងមិនធ្វើទង្វើរទាំងនេះជាមួយមិត្តភក្តិ ឬក៏ សាច់ញាតិរបស់យើង។

និយាយបែបនេះមិនមែនបានន័យថាអោយឪពុកម្តាយនៅក្នុងប្រទេសកម្ពុជាមិនបង្ហាញសេច ក្តីស្រលាញ់ទៅកូនរបស់គាត់ទេ។ ពួកគាត់អាចធ្វើបាន ប៉ុន្តែការបង្ហាញសេចក្តីស្រលាញ់ គឺពិតជាខុសសាច់រឿងគ្នាទាំស្រុង។ ការក្នុង

សម័យខ្មែរក្រហមពួកគេព្យាយាមលប់បំបាត់ ស្នេហា មនោសច្ចេតនា នឹងគ្រួសារជិត៥ឆ្នាំ ហើយឪពុកម្តាយរបស់យើងបានថែរក្សាការ ស្រលាញ់មកដល់ថ្ងៃនេះ នេះគឺជារឿងពិតរបស់មនុស្សជាតិ។

ក្មេងជំនាន់ក្រោយប្រហែលជាយល់ច្រលំតៗគ្នាអំពីអតីតកាល នឹងបច្ចុប្បន្ន។ ឥលូវដោយសារ តែសកលភាវូបនីយកម្ម នឹងការសាយភាយរបស់វប្បធម៌ជាច្រើន ចូលក្នុងស្រុក ក្មេងៗនៅប្រទេសកម្ពុជាបានសម្រេចចិត្តរស់នៅនឹងធ្វើអ្វីខុសពីឪពុកម្តាយរបស់គេ។ ពូកគេ លែងមានអ្វីដែលដូចនឹងឪពុកម្តាយរបស់គេទៀតហើយ ប៉ុន្តែច្រលោះប្រហោងនេះអាច បង្រួមគ្នាបានដោយសេចក្តីស្រលាញ់ នឹងកាពិភាក្សារ។

ប្រសិនបើមានអ្នកណាម្នាក់មកសុំគន្លឹះនៅថ្ងៃបុណ្យនៃសេចក្តីស្រលាញ់ សូមបំផ្លេចនៅការ អោយផ្ការ នឹងការដូរ ប៉ុន្តែអ្នកនៅតែអាចពង្រីកសារថ្ងៃបុណ្យនៃសេចក្តីស្រលាញ់ នឹងស្នេហា ដោយបង្ហាញពីកាស្រលាញ់មួយទៅកាន់មនុស្សម្នាក់សូមបីតែមនុស្សចំឡែក។